ធនាគារពិភពលោក កម្ពុជា
ព្រឹត្តិបត្រព័ត៌មាន



ឆ្នាំទី ៧ លេខ ១០/១១

ខែ តុលា/វិច្ឆិកា ឆ្នាំ ២០០៩

# ត្រៀមលក្ខណៈដើម្បីជួយសង្គ្រោះអាកាសធាតុរបស់យើង៖ ចាប់ផ្តើមធ្វើឥឡូវនេះ ធ្វើទាំងអស់គ្នា និងធ្វើតាមរបៀបផ្សេងៗគ្នា

អង្គុយ នៅលើទបង្ហូរទឹកបាក់បែកមួយ ស្ថិតនៅលើវាលស្រែស្រូវដ៏ធំល្វឹងល្វើយដែលត្រូវបានបំផ្លាញដោយព្យុះកេតសាណាកាលពីខែមុន កសិករ កែវ អឿន បានដកដង្ហើមយ៉ាងវែងនៅពេលដែលសួរថា តើគាត់ទទួលរងគ្រោះយ៉ាងណាខ្លះដោយព្យុះនេះ។ កសិកររូបនេះបានចង្អុលទៅវាលស្រែស្រូវរបស់គាត់ដែលត្រូវបានបំផ្លាញទាំងស្រុង ហើយនិយាយថា "វាលស្រែទំហំមួយហិចតារបស់ខ្ញុំត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង។ ខ្ញុំបារម្ភណាស់ព្រោះវានឹងខ្វះអង្ករហូប" ។

តទៅទំព័រទី ២



*លោក កែវ អឿន ចង្អុលទៅវាលស្រែស្រូវដែលបំផ្លាញដោយព្យុះកេតសាណា។*

# សេដ្ឋកិច្ចរបស់កម្ពុជាសង្ឃឹមថានឹងបានល្អប្រសើរនៅឆ្នាំក្រោយ

កញ្ញា ចរិយា អាយុ ២១ ឆ្នាំ ក្នុងសំលៀកបំពាក់ កាត់បែបរ៉ូបពណិកាប់ស្តាំង និងតុបតែងមុខយ៉ាងស្រស់សោភា បានលើកដៃសំពះស្វាគមន៍ភ្ញៀវដែលកំពុងដើរចូលក្នុងភោជនីយដ្ឋានបៀរហ្គាដិនដែលនាងធ្វើការ បន្ទាប់មកនាងក៏នាំភ្ញៀវទៅកាន់តុមួយ។



*ចរិយា ឈរនៅមុខភោជនីយដ្ឋាន។*

កញ្ញា ចរិយា ធ្វើជាអ្នកទទួលភ្ញៀវ ទើបបានរយៈពេលមួយខែប៉ុណ្ណោះ។ នាងធ្លាប់ធ្វើជាកម្មករកាត់ដេរ ក៏ប៉ុន្តែកាលពីខែមករា ឆ្នាំ ២០០៩ រោងចក្រនោះ បានប្រាប់នាងថា គេមិនអាចបន្តកិច្ចសន្យាឱ្យនាងទៀតទេ ព្រោះគ្មានការងារសម្រាប់នាងនិងមិត្តភក្តិរបស់នាង។

ចរិយា បាននិយាយថា "នៅពេលដែលកិច្ចសន្យាលើកទីពីររបស់ខ្ញុំបានបញ្ចប់មេការបានប្រាប់ខ្ញុំថា រោងចក្រមិនអាចផ្តល់ការងារផ្សេងទៀតឱ្យខ្ញុំបានទេ។ ពេលនោះខ្ញុំព្រួយបារម្ភចំពោះប្រាក់ចំណូលរបស់ខ្ញុំ។ ខ្ញុំមានការលំបាកក្នុងការស្វែងរកការងារធ្វើណាស់" ។

ទោះជាយ៉ាងណាក្តី ក្នុងរយៈពេលមួយខែ ចរិយា រកបានការងារធ្វើជាអ្នកបំរើនៅភោជនីយដ្ឋានមួយនៅភ្នំពេញ។ ក៏ប៉ុន្តែ នៅភោជនីយដ្ឋាននោះ នាងទទួលបានប្រាក់ខែតែ ៣៥ដុល្លារប៉ុណ្ណោះក្នុងមួយខែ តិចជាងពាក់កណ្តាលនៃប្រាក់ខែកម្មករកាត់ដេរ ដែលនាងធ្លាប់ទទួល។

កម្មករកាត់ដេរម្នាក់ទៀតដែលត្រូវបានកាត់រំសាយពីការងារដែលនោះ គឺ សុខ សុភាព ជាស្ត្រីមេម៉ាយមានកូនម្នាក់។ សុភាពរកបានការងារថ្មីមួយនៅរោងចក្រកាត់ដេរមួយផ្សេង

តទៅទំព័រទី ២

# សេដ្ឋកិច្ចរបស់កម្ពុជាសង្ឃឹមថានឹងបានល្អប្រសើរនៅឆ្នាំក្រោយ

***តមកពីទំព័រទី ១***

ទៀត។ ក៏ប៉ុន្តែ នាងទទួលបានប្រាក់ខែទាបជាងច្រើនបើធៀបទៅនឹងរោងចក្រចាស់។ រោងចក្រថ្មីផ្តល់ប្រាក់ខែថេរចំនួន ៥០ ដុល្លារក្នុងមួយខែ និងគ្មានការងារបន្ថែមម៉ោងទេ។ ពីមុននាងទទួលបានប្រាក់ខែចន្លោះពី ៧០ ទៅ ១០០ ដុល្លារក្នុងមួយខែ។

សុភាព បាននិយាយថា "ឥឡូវនេះ ខ្ញុំលំបាកក្នុងការផ្គត់ផ្គង់គ្រួសាររបស់ខ្ញុំ។ ក៏ប៉ុន្តែ មានការងារធ្វើប្រសើរជាងអត់" ។

ចរិយា និង សុភាព គឺជាកម្មករពីរនាក់ក្នុងចំណោមកម្មកររាប់ម៉ឺននាក់ដែលបានបាត់បង់ការងារ នៅពេលដែលកម្ពុជាទទួលរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ ២០០៨។ ឥឡូវនេះ កម្មករមួយចំនួនក្នុងចំណោមកម្មករទាំងនោះ រកបានការងារថ្មីក្នុងវិស័យបំរើសេវា វិស័យកាត់ដេរ ឬផ្នែកសំណង់ ក៏ប៉ុន្តែ កម្មករដទៃទៀត បានវិលត្រលប់ទៅស្រុកកំណើតរបស់ខ្លួនវិញនៅជនបទដើម្បីធ្វើស្រែចំការ។

ថ្មីៗនេះ ធនាគារពិភពលោកបានចេញរបាយការណ៍ថ្មីពាក់កណ្តាលឆ្នាំរបស់ខ្លួនស្តីអំពីសេដ្ឋកិច្ចរបស់កម្ពុជា។ របាយការណ៍នេះ បានឱ្យដឹងថា សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះដល់ដក ២,២ ភាគរយ នៅក្នុងឆ្នាំ២០០៩។ ផលិតផលនាំចេញផ្នែកវិស័យកាត់ដេរ បានធ្លាក់ចុះត្រឹម ២៦ ភាគរយ ក្នុងរយៈពេល ៦ខែដើមឆ្នាំ ២០០៩ បើធៀបនឹងឆ្នាំមុន ចំណែកវិស័យទេសចរណ៍ ក៏បានធ្លាក់ចុះផងដែរ ហើយការអនុម័តលើគំរោងសាងសង់ធ្លាក់ចុះ២៥ភាគរយ។

ផ្ទុយទៅវិញ ជាមួយវិស័យទាំងបីនេះ របាយការណ៍នេះបានបង្ហាញអំពីភាពប្រសើរឡើងនៃផលិតកម្មស្រូវក្នុងកំឡុងឆ្នាំ ២០០៩។ ហើយរំពឹងថាវាជាសញ្ញាណនៃការងើបរើបៗឡើងវិញ នៅក្នុងឆ្នាំ២០១០ ដែលនឹងកើនឡើង ៤ភាគរយ នេះបើតាមការរំពឹងទុក។ វិស័យសំខាន់ៗដូចជា សំណង់ នឹងឈប់ធ្លាក់ចុះទៀតហើយ ដោយសារតែលំហូរចូលនៃមូលធនថ្មីៗ ការកក់បន្ទប់សណ្ឋាគារ ក៏ត្រូវបានគេរំពឹងថានឹងមានលក្ខណៈល្អប្រសើរឡើងវិញផងដែរ។

ក៏ប៉ុន្តែ ក៏នៅមានសញ្ញានៃសម្ពាធលើអាជីវកម្ម។ ឱកាសទទួលបានហិរញ្ញវត្ថុ (ពីធនាគារក្នុងស្រុក ឬវិនិយោគទុនបរទេស) នៅមិនទាន់មានសកម្មភាពខ្លាំងក្លានៅឡើយ។ ការចុះបញ្ជីក្រុមហ៊ុនថ្មី បានធ្លាក់ចុះយ៉ាងគំហុក គឺ៤០ ភាគរយ នៅក្នុងឆមាសទីមួយ ឆ្នាំ ២០០៩ បើធៀបទៅនឹងឆ្នាំមុន ហើយ ១៨ ភាគរយ នៃរោងចក្រកាត់ដេរដែលបានបើកនៅដើមឆ្នាំនេះ បានបិទទ្វារវិញ រោងចក្រមួយចំនួនផ្សេងទៀតកំពុងប្រឈម នឹងបញ្ហាសន្ទនិយភាព (ប្រាក់ ឬរបស់របរដែលអាចដូរជាសាច់ប្រាក់បានឆាប់)។ បំណុល របស់គ្រួសារ ក៏មានការកើនឡើងផងដែរ ក្រោមសម្ពាធនៃតម្លៃទំនិញកាន់តែថ្លៃនៅក្នុងឆ្នាំ២០០៨ និងប្រាក់ចំណូលកាន់តែទាបនៅក្នុងឆ្នាំ ២០០៩។ របាយការណ៍នេះបានឱ្យដឹងទៀតថា ភាពងាយទទួលរងគ្រោះលើអាជីវកម្ម និងគ្រួសារ នឹងអាចធ្វើឱ្យទន់ខ្សោយដល់ការងើបឡើងវិញនេះផងដែរ។

ជាការឆ្លើយតបទៅនឹងវិបត្តិសេដ្ឋកិច្ចពិភពលោក រដ្ឋាភិបាលកម្ពុជាកំពុងតែធ្វើកំណែទំរង់គោលនយោបាយផ្សេងៗ រួមទាំងវិធានការសារពើពន្ធជាច្រើន ក្នុងនោះ មានសកម្មភាពខាងក្រៅ ដូចជា សន្និសញ្ញាពាណិជ្ជកម្ម និងវិនិយោគទុនមួយចំនួន ត្រូវបានចុះហត្ថលេខារួមទាំងតាមរយៈអាស៊ាន។ បច្ចុប្បន្ន កម្ពុជាទទួលបាននូវសិទ្ធិអនុគ្រោះ សម្រាប់ទំនិញគ្រប់យ៉ាង លើកលែងតែគ្រឿងសព្វាវុធ នាំចេញទៅប្រទេសជាសមាជិកនៃសហភាពអឺរ៉ុប។ ផ្នែកខាងក្នុង មជ្ឈមណ្ឌលមជ្ឈត្តភាពជាតិមួយនឹងត្រូវបានបង្កើតឡើងក្នុងពេល ឆាប់ៗខាងមុខ ហើយកំណែទំរង់សម្របសម្រួលពាណិជ្ជកម្ម និងកិច្ចប្រឹងប្រែងជំរុញវិនិយោគកំពុងតែបន្ត។ **(សម្រាប់ព័ត៌មានលំអិត សូមអានបទសម្ភាសជាមួយអ្នកសេដ្ឋកិច្ចជាន់ខ្ពស់ប្រចាំកម្ពុជារបស់ធនាគារពិភពលោក)។**

# ...ចាប់ផ្តើមធ្វើឥឡូវនេះ ធ្វើទាំងអស់គ្នា និងធ្វើតាមរបៀបផ្សេងៗគ្នា

***តមកពីទំព័រទី១***

លោក អឿន មានស្រែប្រហែលជាពីរហិចតា។ រៀងរាល់ឆ្នាំ គាត់ប្រមូលផលបានប្រហែលជា ៣ តោនស្រូវ ដែលអាចផ្គត់ផ្គង់សមាជិកទាំង៧ នាក់ ក្នុងគ្រួសាររបស់គាត់។ ក៏ប៉ុន្តែ ព្យុះកេតសាណា បានបំផ្លាញស្រូវរបស់គាត់អស់ចំនួនជាងពាក់កណ្តាល។

អង្គុយនៅក្រោមដំបូលតង់ប្លាស្ទិកពណ៌ខៀវនៅកន្លែងផ្ទះបែកបាក់របស់គាត់ អ្នកស្រី អ៊ុំ ស៊ុភ័ណ្ឌ អាយុ ៣៩ឆ្នាំ ដែលមានកូន ៤នាក់ បាន និយាយថា ព្យុះនេះ បានបំផ្លាញផ្ទះឈើថ្មីរបស់គាត់ដែលសង់អស់តម្លៃ ៧ លានរៀល (១៧០០ ដុល្លារ) សំលៀកបំពាក់ទាំងអស់របស់គ្រួសារគាត់ សម្ភារៈសិក្សា របស់កូនគាត់ និងសម្ភារៈ ផ្ទះបាយ ដូចជា ចាន និងឆ្នាំង ។ល។ ហើយវាបានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់គាត់ ដោយជាងពាក់កណ្តាលនៃផលស្រូវរបស់គាត់ត្រូវបានបំផ្លាញ និងកូនប្រុសម្នាក់របស់គាត់បានរងរបួស។

អ្នកស្រីបានបន្ថែមទៀតថា "វាពិបាកណាស់ សម្រាប់ប្តីខ្ញុំ និងខ្ញុំ ទៅរកប្រាក់ ៣ លានរៀល (៧០០ដុល្លារ) ដើម្បីសាងសង់ផ្ទះរបស់យើងឡើងវិញ។ ឥឡូវនេះ ពួកយើងកំពុងរស់នៅក្នុងផ្ទះបាយតូចរបស់យើង (ទំហំ ២ម គុណនឹង៣ម)។ ក្តីបារម្ភធំបំផុត របស់យើង គឺស្រូវអង្ករសម្រាប់ហូប និងប្រាក់ សម្រាប់ផ្គត់ផ្គង់ការសិក្សារបស់កូន"។

លោក អឿន និងអ្នកស្រី ស៊ុភ័ណ្ឌ ស្ថិតក្នុងចំណោមជនរងគ្រោះជិតពាន់គ្រួសារនៅក្នុង

***តទៅទំព័រទី ៤***

# វិស័យកសិកម្ម និង ទេសចរណ៍ នឹងរំពឹងទុកថាមានការរីកចំរើន

***របាយការណ៍ប្រចាំឆមាសស្តីអំពីសេដ្ឋកិច្ចនៅអាស៊ីបូព៌ា ដែលចុះផ្សាយអំពីកំណើនសេដ្ឋកិច្ចក្នុងតំបន់ និងរួមទាំងសេដ្ឋកិច្ចកម្ពុជា បានចេញផ្សាយកាលពីដើមខែវិច្ឆិកា ឆ្នាំ ២០០៩។ ព្រឹត្តិប័ត្រប្រចាំខែរបស់ធនាគារពិភពលោកប្រចាំកម្ពុជា មានឱកាស បានជួបសម្ភាសជាមួយអ្នកសេដ្ឋកិច្ចជាន់ខ្ពស់ប្រចាំប្រទេសរបស់ធនាគារពិភពលោក ស្តីអំពីទស្សនវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។***

***សូមលោកជំរាបខ្ញុំបានទេតើទស្សនវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន នេះមានស្ថានភាពដូចម្តេច?***

បន្ទាប់ពីកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សក្នុងរយៈពេលមួយទសវត្សរ៍ សេដ្ឋកិច្ចរបស់កម្ពុជាកំពុងធ្លាក់ចុះដល់ដក ២,២ ភាគរយនៅក្នុងឆ្នាំ ២០០៩។ ការប៉ាន់ប្រមាណរបស់យើងបង្ហាញឱ្យឃើញអំពីស្ថានភាពប្រសើរឡើងសម្រាប់ឆ្នាំ ២០១០ ដែលភាពប្រសើរឡើងវិញនេះ មានល្បឿយឺត និងកើនឡើង ៤ ភាគរយ។ ក៏ប៉ុន្តែ ភាពប្រសើរឡើងវិញនេះ នឹងត្រូវបានពន្លឿនដោយសារបទដ្ឋាននៃកំណើនដ៏ឆាប់រហ័សរបស់កម្ពុជាក្នុងកំឡុងពីឆ្នាំ ១៩៩៨ ដល់ ២០០៨។ ការវិភាគរបស់ យើងលើសេដ្ឋកិច្ចបង្ហាញថាភាពប្រសើរឡើងវិញនេះ នឹងត្រូវបានរុញច្រានទៅមុខដោយកំណើនជាបន្តលើវិស័យកសិកម្ម និងការងើបរើបឡើងវិញលើវិស័យទេសចរណ៍ដែលគេបានរំពឹងទុក។ ភាពប្រសើរឡើងវិញលើផ្នែកសំណង់ នឹងមានសភាពយឺតចំណែកឯភាពមិនប្រាកដប្រជាលើវិស័យកាត់ដេរនៅតែមានកំរិតខ្ពស់។



***លោក ស្ទេហ្វាន ហ្គីមប៊ែរ អ្នកសេដ្ឋកិច្ចជាន់ខ្ពស់របស់ធនាគារពិភពលោកប្រចាំកម្ពុជា ។***

អនុញ្ញាតឱ្យខ្ញុំរំលឹកលោកអំពីភាពមិនប្រាកដប្រជាជុំវិញការព្យាករណ៍លើសេដ្ឋកិច្ច។ មានសំណួរជាច្រើននៅក្នុងប្រទេសកម្ពុជា ពីព្រោះស្ថាប័នជាច្រើន ដូចជាស្ថាប័នរបស់យើងមានការព្យាករណ៍អំពីសេដ្ឋកិច្ចខុសៗគ្នាបន្តិចបន្តួច ឬបានកែតំរូវការព្យាករណ៍ ផ្នែកសំខាន់ៗរបស់ពួកគេនៅឆ្នាំនេះ។ វាជាការសំខាន់ដែលត្រូវយល់ថា ការព្យាករណ៍នេះ ឆ្លុះបញ្ចាំងយ៉ាងច្រើនអំពីភាពមិនប្រាកដប្រជាក្នុងសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន។ ការព្យាករណ៍ ជាច្រើនលើសេដ្ឋកិច្ចសកលលោក ក៏ត្រូវបានកែសំរួលជាច្រើនដងផងដែរនៅឆ្នាំនេះ ហើយអ្នកវិភាគជាច្រើននៅតែប្រកាន់ទស្សនៈខុសៗ គ្នាអំពីកំលាំងនៃការងើបឡើងវិញនេះ។ ក្រៅពីនេះ រចនាសម្ព័ន្ធនៃសេដ្ឋកិច្ចរបស់កម្ពុជា បានផ្លាស់ប្តូរគួរឱ្យកត់សំគាល់ក្នុងរយៈពេល ១០ឆ្នាំកន្លងទៅ (គេបានចាត់ទុកថាវិស័យកសិកម្មធ្លាប់មានកំណើនស្មើនឹងពាក់កណ្តាលនៃផលិតផលសរុបក្នុងស្រុកហើយបច្ចុប្បន្នមានកំណើនតិចជាងមួយ/បី) ហើយដែលបង្កើននូវភាពមិនប្រាកដប្រជាអំពីប្រតិកម្ម របស់សេដ្ឋកិច្ចទៅលើការផ្លាស់ប្តូរដ៏ច្រើននៅក្នុងសេដ្ឋកិច្ចពិភពលោក។ បន្ថែមពីលើអ្វីដែលយើងមិនអាចទាយទុកមុនបាន (ឧទាហរណ៍ពីព្រោះផលិតផលរបស់ផ្នែកកសិកម្មពឹងផ្អែកលើអាកាសធាតុ) មានភាពមិនប្រាកដប្រជា មួយចំនួននៅឆ្នាំនេះ ដូចជាវិស័យទេសចរណ៍ អាចប្រសើរឡើងវិញយឺតៗ ដោយសារតែវីរុស H1N1 ឬប្រសិនបើការងើបរើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក មានលក្ខណៈយឺតយ៉ាវ ឬក៏ផ្នែកសំណង់អាចប្រសើរឡើងវិញលឿនជាង ដោយសារតែតម្លៃសម្ភារៈសំណង់បានធ្លាក់ចុះ។

***វិស័យកសិកម្មគឺជាវិស័យដ៏សំខាន់មួយក្នុងចំណោមវិស័យសំខាន់ៗជាច្រើនដែលចូលរួមចំណែកក្នុងផលិតផលសរុបក្នុងស្រុក។ ថ្មីៗនេះកម្ពុជាបានទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីព្យុះកេតសាណា ហើយស្រូវ និង ហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវបានបំផ្លិចបំផ្លាញ។ តើវាធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាយ៉ាងដូចម្តេចដែរនៅឆ្នាំ ២០១០?***

រដ្ឋាភិបាល បានស្នើឱ្យធនាគារពិភពលោកគាំទ្រដល់ការវាយតម្លៃលើផលប៉ះពាល់របស់ព្យុះកេតសាណាអំពីតំរូវការចាំបាច់ក្រោយគ្រោះមហន្តរាយនេះ។ ក្រុមការងារវាយតម្លៃធំៗ មួយ ដែលរួមមាន ទីភ្នាក់ងារជាច្រើន

តទៅទំព័រទី ៥

# ...ចាប់ផ្តើមធ្វើឥឡូវនេះ ធ្វើទាំងអស់គ្នា និងធ្វើតាមរបៀបផ្សេងៗគ្នា




***ប្រធានគ្រប់គ្រងធនាគារពិភពលោក លោក ឈីម៉ាវ ហ្វាន ថ្លែងសុន្ទរកថា បិទវេទិកាជាតិស្តីពីការប៉ំរែបំរួលអាកាសធាតុ ។***

***តមកពីទំព័រទី២***

ដែលបានទទួលរងគ្រោះដោយព្យុះកេតសាណា កាលពីចុងខែកញ្ញា ឆ្នាំ ២០០៩។

បាតុភូតធម្មជាតិដូចជាព្យុះកេតសាណានេះ ត្រូវបានគេជឿថា កើតឡើងដោយសារតែបំរែបំរួលអាកាសធាតុ។ បីសប្តាហ៍ បន្ទាប់ពីព្យុះនេះបានបក់បោកមកលើប្រទេសកម្ពុជា (នៅក្នុងខេត្ត កំពង់ធំ ព្រះវិហារ សៀមរាប និង ខេត្តជិតខាងជាច្រើនទៀត ដែលមានប្រជាជន កម្ពុជា ចំនួន ៤៣ នាក់ បានស្លាប់បាត់បង់ជីវិត វេទិកាជាតិលើកទីមួយស្តីអំពីបំរែបំរួលអាកាសធាតុបានប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ ដើម្បីពិភាក្សាអំពីវិធីសម្របតាមបំរែបំរួលអាកាសធាតុ និងកាត់បន្ថយឥទ្ធិពលរបស់វា។

ថ្លែងនៅក្នុងពិធីបើកវេទិកានេះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានជំរុញឱ្យបណ្តាប្រទេសទាំងអស់ចាត់វិធានការក្នុងពេលឥឡូវនេះដើម្បីឆ្លើយតបទៅនឹងបំរែបំរួលអាកាសធាតុ។

សម្តេច បានមានប្រសាសន៍ថា "បំរែបំរួលអាកាសធាតុគឺ ជាបញ្ហាប្រឈមដ៏ចំបង ដែលពិភពលោកកំពុងជួបប្រទះដែលមានសក្តានុពលអាចកែប្រែដំណើរវិវិវឌ្ឍន៍នៃអារ្យធម៌មនុស្សជាតិ បើពុំមានវិធានការឆ្លើយតបឱ្យបានសមស្របនិងទាន់ពេលវេលាទេនោះ ។ បញ្ហាពុំបញ្ឈប់ត្រឹមព្រំប្រទល់របស់ប្រជាជាតិណាមួយនោះទេ ពីព្រោះផែនដីយើងមានបរិយាកាសតែមួយគត់។ ទាំងប្រទេសអ្នកមាន និងប្រទេសក្រីក្រសុទ្ធតែទទួលរងគ្រោះដូច គ្នាដោយសារបញ្ហាប្រែប្រួលអាកាសធាតុ ។

បន្ទាប់ពីពិធីបើកវេទិកានេះ សិក្ខាសាលារយៈពេលពីរថ្ងៃ វាគ្មិនបានពិភាក្សាអំពីវិធីកាត់បន្ថយបំរែបំរួលអាកាសធាតុលើភាពក្រីក្រ និងប្រជាជន ជាពិសេស ស្ត្រី និងកុមារ និងទៅលើធនធានធម្មជាតិ ។ វាគ្មិន ក៏ពិភាក្សាផងដែរអំពីវិធីសាស្ត្រទប់ស្កាត់បំរែបំរួលអាកាសធាតុ តាមរយៈការឆ្លើយតប ដូចជាថាមពលដែលកកើតឡើងវិញ និងប្រើប្រាស់កាបោនទាប ហិរញ្ញប្បទានកាបោន ធនធានថ្មីៗ ឧបករណ៍ថ្មីៗ និងបច្ចេកវិទ្យាថ្មីៗ។ សិក្ខាកាមទាំងអស់ក៏បានពិភាក្សាផងដែរអំពីការសម្របតាមបំរែបំរួលអាកាសធាតុនិងពីវិធីប្រែក្លាយការយល់ដឹងអំពីបំរែបំរួលអាកាសធាតុទៅជាការចាត់វិធានការទប់ស្កាត់។

នៅក្នុងពិធីសន្និសីទសារព័ត៌មាន ឯកឧត្តមទេសរដ្ឋមន្ត្រី ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន មានប្រសាសន៍ថា ក្រសួងបរិស្ថាន បានស្នើឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកាត់បន្ថយពន្ធនាំចូលសម្រាប់ទំនិញនានា ដែលអាចកាត់បន្ថយបំភាយឧស្ម័នកាបោន ហើយជំរុញឱ្យប្រើប្រាស់ថាមពលដែលអាចកកើតឡើងវិញ។ ចាប់តាំងពីពេលនោះមកពន្ធ នាំចូលត្រូវបានកាត់បន្ថយពី ៣៥

***តមកពីទំព័រទី៥***



***ផ្លូវដែលពោរពេញដោយកំទិចកំទីគ្រឿងដំបូលផ្ទះដែលបំផ្លាញដោយព្យុះកេតសាណានៅស្រុកសណ្តាន់ខេត្តកំពង់ធំ ។***

# វិស័យកសិកម្ម និង ទេសចរណ៍ នឹងរំពឹងទុកថាមានការរីកចំរើន



*លោក ស្ទេហ្វាន ហ៊្គីមប៊ែរ ជំរាបជូនអ្នកសារព័ត៌មានស្ដីអំពីបច្ចុប្បន្នភាពសេដ្ឋកិច្ចប្រចាំអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។*

**តមកពីទំព័រទី៣**

របស់រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ជាច្រើន រួមទាំងធនាគារពិភពលោក កំពុងតែធ្វើការងារនេះ។ ការវាយតម្លៃនេះនឹងធ្វើឱ្យយើងយល់ដឹងកាន់តែច្រើនឡើងអំពីផលប៉ះពាល់និងតំរូវការចាំបាច់ដើម្បីកាត់បន្ថយ ហានិភ័យបែបនេះក្នុងពេលអនាគត។

ការវាយតម្លៃបឋមរបស់យើងផ្អែក លើទិន្នន័យ ប្រមូលបានដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានឱ្យដឹងថា មានគ្រួសារប្រមាណ ១៨០ ពាន់គ្រួសារ បានទទួលរងប៉ះពាល់ និងវាលស្រូវរាប់ពាន់ហិចតា ត្រូវខូចខាត។ ប្រសិទ្ធិភាពម៉ាក្រូសេដ្ឋកិច្ចអាចនឹងមិនមានទំហំធំទេ (ប្រហែលស្ថិតក្នុងលំដាប់ពី 0,១ ទៅ 0,៣ ភាគរយនៃផលិតផលសរុប ក្នុងស្រុក) ក៏ប៉ុន្តែ ប្រសិទ្ធិភាពនេះគ្របដណ្ដប់លើភាពខុសគ្នាជាច្រើន។ ទីមួយ ខេត្តមួយចំនួន

**តមកពីទំព័រទី៦**

# ...ចាប់ផ្តើមធ្វើឥឡូវនេះ ធ្វើទាំងអស់គ្នា និងធ្វើតាមរបៀបផ្សេងៗគ្នា

**តមកពីទំព័រទី៤**

ភាគរយ មកនៅ ៧ ភាគរយ សម្រាប់បន្ទះស្រូបកំដៅព្រះអាទិត្យ ហើយបានលុបចោលពន្ធនាំចូលលើម៉ាស៊ីនភ្លើងដើរដោយកំលាំងខ្យល់ និងម៉ាស៊ីនភ្លើងខ្នាតតូចដើរដោយចរន្តទឹក។ ឯកឧត្តម ក៏បានមានប្រសាសន៍ផងដែរថា កិច្ចពិភាក្សារយៈពេលពីរថ្ងៃនេះ បានផ្តល់នូវការគាំទ្រដ៏ខ្លាំងក្លាដល់កម្ពុជា ដើម្បីអភិវឌ្ឍសមត្ថភាព កៀងគរធនធានហិរញ្ញវត្ថុ និងជួយកម្ពុជា រៀបចំសម្រាប់កិច្ចចរចានៅឯសន្និសីទស្ដីអំពីបំរែបំរួលអាកាសធាតុនៅទីក្រុងខូផិនហេហ្គេន នាខែធ្នូ ឆ្នាំ ២០០៩។

កម្ពុជា ជាប្រទេសនាំមុខគេក្នុងចំណោមបណ្ដាប្រទេសកំពុងអភិវឌ្ឍក្នុងការរៀបចំគម្រោងកម្មវិធីសម្របតាមបំរែបំរួលអាកាសធាតុ (គឺកម្មវិធីសកម្មភាពសម្របតាមបំរែបំរួលអាកាសធាតុថ្នាក់ជាតិ (NAPA) ដែលកំណត់អំពីអាទិភាពបន្ទាន់ៗ។ រដ្ឋាភិបាលក៏បានបង្កើត គណៈកម្មាធិការជាតិសម្រាប់បំរែបំរួលអាកាសធាតុផងដែរ។ វិធានការទាំងនេះបានដាក់ប្រទេសកម្ពុជានៅក្នុងគោលជំហរដ៏រឹងមាំមួយ ក្នុងការទាញយកអត្ថប្រយោជន៍ពេញលេញពីកិច្ចព្រមព្រៀងរបស់ខ្លួន ជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន ៩ នៃកម្មវិធីសាកល្បងសម្រាប់ភាពទប់ទល់នឹងបំរែបំរួលអាកាសធាតុ (PPCR) ថ្មីមួយ។

ក្រោមកម្មវិធី PPCR កម្ពុជានឹងទទួលបាន ទឹកប្រាក់ចន្លោះពី៣០លានដុល្លារ ទៅ ៦០ លានដុល្លារ ដើម្បីលើកកំពស់សមត្ថភាពស្ថាប័នរបស់ខ្លួន និងដើម្បីគាំទ្រដល់កម្មវិធីវិនិយោគទ្រង់ទ្រាយធំនៅក្នុងតំបន់ ដែលនឹងបង្កើនអាទិភាពអភិវឌ្ឍន៍ថ្នាក់ជាតិ និងធ្វើឱ្យកម្មវិធីនេះកាន់តែធន់ទៅនឹងបំរែបំរួលអាកាសធាតុ។

នៅក្នុងពិធីបិទវេទិកានេះ លោក ឈីម៉ាវ ហ្វាន ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំកម្ពុជាមានប្រសាសន៍ថា បំរែបំរួលអាកាសធាតុ គឺជាបញ្ហាបន្ទាន់មួយសម្រាប់មនុស្សគ្រប់រូបនិងសម្រាប់ប្រទេសទាំងអស់។ ក៏ប៉ុន្តែ លោកបានថ្លែងថាភាពបន្ទាន់នេះវាចាំបាច់ខ្លាំងណាស់សម្រាប់ប្រជាជននៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍ ជាពិសេសនៅក្នុងបណ្ដាប្រទេស ដែលមានការអភិវឌ្ឍតិចតួច ដូចជា ប្រទេសកម្ពុជា: វិធីទប់ទល់នឹងអាកាសធាតុដែលកំពុងប្រែប្រួល ដែលនឹងមានផលប៉ះពាល់មកលើលទ្ធភាពទទួលបានស្បៀងអាហារ ទឹក ថាមពល ទីជម្រក ការថែទាំសុខភាពមនុស្ស និងចីរភាពនៃជីវភាពរស់នៅ។

លោក ជីម៉ែវ ហ្វាន បានបន្ថែមទៀតថា "បំរែបំរួលអាកាសធាតុ អាចរក្សាឱ្យនៅក៏រិត ២ សង់ទីក្រាដ។ ប៉ុន្តែ ដើម្បីធ្វើឱ្យវាកើតចេញជារូបរៀងបាន គ្រប់ប្រទេសត្រូវធ្វើនៅពេលនេះ ធ្វើទាំងអស់គ្នា និងធ្វើតាមបែបផ្សេងៗគ្នា" ។

# វិស័យកសិកម្ម និង ទេសចរណ៍ នឹងរំពឹងទុកថាមានការរីកចំរើន

***តមកពីទំព័រទី៥***

ទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ជាពិសេស នៅខេត្តកំពង់ធំ និងភាគព្យសាន។ ទីពីរ គ្រួសារដែលងាយរងគ្រោះបំផុត (ដែលមានទ្រព្យសម្បត្តិ និងប្រាក់សន្សំតិចតួច) បានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

***វាហាក់ដូចជាមានលក្ខណៈធ្ងន់ធ្ងរ ប្រសិនបើប្រៀបធៀបទៅនឹងឆ្នាំ ២០០៨។ តើវាប៉ះពាល់ដល់ការងារនៅកម្ពុជា និង ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រយ៉ាងដូចម្តេច?***

មានតែមួយភាគប្រាំប៉ុណ្ណោះនៃគ្រួសារទាំងអស់ មានការងារធ្វើក្នុងវិស័យនានាដែលបានទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិនេះ( វិស័យកាត់ដេរ សំណង់ និងទេសចរណ៍)។ គ្រួសារនៅទីក្រុង និងគ្រួសារមានជីវភាពជាងគេ ទំនងជានឹងរងផលប៉ះពាល់ច្រើនតាមរយៈវិស័យទាំងនេះ ។ ក៏ប៉ុន្តែ ផលប៉ះពាល់លើប្រាក់ចំណូលមានទំហំធំបំផុតក្នុងចំណោមគ្រួសារក្រីក្រជាងគេ និងគ្រួសារនៅជនបទដែលការងារទាំងនោះ បានបង្កើតប្រាក់ចំណូលដោយផ្ទាល់។ ការប៉ាន់ប្រមាណជាច្រើន បង្ហាញថា វិបត្តិនេះអាចធ្វើឱ្យជនរងគ្រោះ ធ្លាក់ចូលក្នុងភាពក្រីក្រថែមពី ១ ទៅ ៤ ចំណុចនៃភាគរយ ក្នុងចន្លោះពីឆ្នាំ ២០០៧ ដល់ ២០១០ : ម្យ៉ាងទៀត បើប្រៀបធៀបទៅនឹងទសវត្សរ៍កន្លងទៅ នៅពេលដែលចំនួនប្រជា ជនក្រីក្រត្រូវបានកាត់បន្ថយបន្តិចម្តងៗ វិបត្តិនេះ នឹងកត់សំគាល់អំពីការធ្លាក់ចុះនៅក្នុងនិន្នាការនេះ ឬក៏ដើរថយក្រោយវិញ។

ប្រហែលជាដូចគ្នាអញ្ចឹងដែរ ជាពិសេស គឺចំនួនយុវជនកម្ពុជាក្មេងៗដ៏ច្រើនដែលចូលទៅក្នុងទីផ្សារការងាររៀងរាល់ឆ្នាំ (ប្រហែល ២៥០០០០នាក់)។ បញ្ហាប្រឈមគឺសម្រាប់ប្រទេស ដើម្បីបង្កើតការងារដ៏ច្រើននេះជារៀងរាល់ឆ្នាំ។ បញ្ហានេះទាមទារឱ្យពង្រីកសេដ្ឋកិច្ច បង្កើនផលិតផលកសិកម្ម ច្រើនប្រភេទព្រមទាំងផ្នែកឧស្សាហកម្មចំរុះដែលបង្កើតការងារច្រើន (ដូចជាវិស័យកាត់ដេរ ដែលទទួលបានជោគជ័យក្នុងទសវត្សរ៍កន្លងទៅ)។

បញ្ហាប្រឈមមួយទៀតគឺថាដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតម្លៃម្ហូបអាហារនៅដើមឆ្នាំ ២០០៨ និងការបាត់បង់ការងារ និងប្រាក់ចំណូលជាច្រើននៅចុងឆ្នាំ ២០០៨ និង ២០០៩ គ្រួសារមួយចំនួនបានខ្ចីបំណុលគេ ឬបានលក់ទ្រព្យសម្បត្តិ(ដូចជាដី)។ បញ្ហានេះធ្វើឱ្យគ្រួសារទាំងនេះកាន់តែងាយរង គ្រោះថែមទៀតក្នុងពេលអនាគត ប្រសិនបើពួកគេមិនអាចបង្កើតប្រាក់ចំណូលចាំបាច់សម្រាប់ រក្សាកំរិតនៃការប្រើប្រាស់របស់ពួកគេបានទេនោះ។



***លោក ស្ទេហ្វាន ហ្គីមប៊ែរ : "ការព្យាករណ៍បានបង្ហាញថា វិបត្តិអាចបន្ថែមពី ១ ទៅ ៤ ចំណុចភាគរយ ដល់ភាពក្រីក្ររវាងឆ្នាំ ២០០៧ និង ២០១០"។***